រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥

# សេចក្តីថ្លែងការណ៍រួមស្តីពីទិវាប្រជាធិបតេយ្យអន្តរជាតិៈ

# ការការពារសិទ្ធិសេរីភាពបញ្ចេញមតិ សិទ្ធិសេរីភាពប្រមូលផ្តុំ និងសិទ្ធិសេរីភាពចូលរួមសមាគម

សមាគម និងអង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាលនៅកម្ពុជា សូមចូលរួមអបអរសាទរចំពោះទិវាប្រជាធិបតេយ្យអន្តរជាតិលើទី៨។ សន្និបាតសាកលរបស់អង្គការសហប្រជាជាតិឆ្នាំ២០០៧ បានចេញសេចក្តីសម្រេចមួយដែលជម្រុញ និងលើកទឹកចិត្តឲ្យរដ្ឋាភិបាលពង្រឹងកម្មវិធីគោលនយោបាយជាតិដើម្បីលើកស្ទួយលទ្ធិប្រជាធិបតេយ្យ។ ហើយសន្និបាតនោះបានសម្រេចយក ថ្ងៃទី១៥ ខែកញ្ញា ជារៀងរាល់ឆ្នាំជាទិវាប្រជាធិបតេយ្យអន្តរជាតិ។ **«ឱកាសសម្រាប់សង្គមស៊ីវិល»** គឺជាប្រធានបទរបស់អង្គការសហប្រជាជាតិសម្រាប់ទិវាប្រជាធិបតេយ្យអន្តរជាតិឆ្នាំ២០១៥នេះ។ ប្រធានបទនេះជាការរំលឹកដល់រដ្ឋាភិបាលទាំងអស់ថា សញ្ញាណនៃប្រជាធិបតេយ្យស្ថិតស្ថេរ និងជោគជ័យ គឺជាវត្តមាននៃការចូលរួមដោយសេរីរបស់សង្គមស៊ីវិល ហើយស្របពេលដែលសង្គមស៊ីវិលជួយធ្វើឲ្យរដ្ឋាភិបាលមានទំនួលខុសត្រូវ។

យោងមាត្រា៥១ថ្មី នៃរដ្ឋធម្មនុញ្ញ ប្រទេសកម្ពុជាប្រកាន់របបប្រជាធិបតេយ្យសេរីពហុបក្ស និង មាត្រា៣៥ មាត្រា៣៧ មាត្រា៤១ និងមាត្រា៤២ និងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយមាត្រា១៩ មាត្រា២១ និង មាត្រា២២ បានការពារសិទ្ធិចូលរួមក្នុងនយោបាយ សិទ្ធិធ្វើកូដកម្ម និងបាតុកម្មដោយសន្តិវិធី សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ រាជរដ្ឋាភិបាលត្រូវមានកាតព្វកិច្ចការពារ និងលើកស្ទួយនូវការអនុវត្តន៍សេរីភាពទាំងបីរួមមាន ការបញ្ចេញមតិ ការប្រមូលផ្តុំ និងការបង្កើតសមាគម។ ក្នុងរយៈពេលចុងក្រោយនេះ ជាពិសេសចាប់តាំងក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ ការអនុវត្តន៍របស់ប្រជាពលរដ្ឋនូវសិទ្ធិសេរីភាពជាមូលដ្ឋានទាំងបីបាននិងកំពុងរឹតត្បិត ជាមួយការរំលោភអំណាច និងការបង្កើតច្បាប់ដែលកំហិតដល់សិទ្ធិសេរីភាពទាំងនោះ។

រាជរដ្ឋាភិបាល និងអាជ្ញាធរត្រូវបញ្ឈប់នូវរាល់សកម្មភាពគំរាមកំហែងទៅលើសកម្មជន ប្រជាពលរដ្ឋដែលព្យាយាមអនុវត្តសិទ្ធិសេរីភាពទាំងនោះដោយសន្តិវិធី។ ការរឹតត្បិតការអនុវត្តន៍សិទ្ធិទាំងនោះ ឈានរហូតដល់មានការចាប់ ឃុំខ្លួន និងផ្តន្ទាទោសព្រហ្មទណ្ឌដល់ប្រជាពលរដ្ឋជាដើម ហើយចំណាត់ការនោះត្រូវបានគេមើលឃើញថា មិនស្របតាមបញ្ញត្តិច្បាប់ និងនីតិវិធីជាធរមាន។

សមាគម និងអង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាល នៅកម្ពុជា ទាមទារយ៉ាងទទូចឲ្យដោះលែងប្រជាពលរដ្ឋទាំងនោះ ព្រមទាំងទម្លាក់ការចោទប្រកាន់ពាក់ព័ន្ធនឹងការអនុវត្តន៍សិទ្ធិជាមូលដ្ឋានខាងលើនេះ។ យ៉ាងហោចណាស់រហូតមកដល់ពេលនេះ មានប្រជាពលរដ្ឋដែលជាសកម្មជនសង្គម និងសកម្មជននយោបាយចំនួន ២១ នាក់[1] ត្រូវបានចាប់ឃុំខ្លួនដោយអាជ្ញាធរ និងផ្តន្ទាទោសឲ្យជាប់ពន្ធនាគារដោយស្ថាប័នតុលាការ បន្ទាប់ពីពួកគេបាន និងព្យាយាមអនុវត្តន៍សេរីភាពជា

[1] ១,មាជ សុវណ្ណារ៉ា ២,អ៊ុក ពេជ្យសំណាង ៣,អឿ ណារិទ្ធិ ៤,ទេព ណារិន ៥,ឃិន ជំរឿន ៦,ស៊ុំ ពុទ្ធី ៧,កែ ឃីម ៨,សាន គឹមហេង ៩,នាង សុឃុន ១០,សាន សីហៈ ១១,អាន បឋម ១២,ជា វណ្ណា(សង្ឃ) ១៣,ដាវ ទេព្យ(សង្ឃ) ១៤,ហុង សុខហួរ ១៥,រឿន ចិត្រា ១៦,យា ថុង ១៧,យ៉ុង គឹមហួរ ១៨,គឹម វ៉ាយ៉ា ១៩,ស៊ីម សំណាង ២០,ទ្រី សុរិគា ២១,សាន់ ម៉ាឡា

មូលដ្ឋានទាំងនោះ។ ការចាប់ឃុំខ្លួន និងផ្តន្ទាទោសប្រជាពរដ្ឋទាំងនោះគឺផ្ទុយពីរដ្ឋធម្មនុញ្ញ និងកតិកាសញ្ញាអន្តរជាតិដែលកម្ពុជាក៏ជារដ្ឋភាគីផងដែរ។

ការអនុវត្តន៍សិទ្ធិបញ្ចេញមតិ សិទ្ធិប្រមូលផ្តុំ និងសិទ្ធិបង្កើតអង្គការសមាគមរបស់ប្រជាពលរដ្ឋ គឺលក្ខខណ្ឌចាំបាច់ដ៏សំខាន់នៃដំណើរការប្រជាធិបតេយ្យសេរីពហុបក្ស។ សមាគម និងអង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាលនៅកម្ពុជា សូមអំពាវនាវ និងជំរុញលើកទឹកចិត្តស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការចូលរួមក្នុងការស្តារស្ថានភាពបច្ចុប្បន្ននៃសេរីភាពជាមូលដ្ឋានទាំងបីឡើងវិញ ដើម្បីធានាថាប្រទេសកម្ពុជាពិតជាប្រកាន់របបលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។

**ទំនាក់ទំនងព័ត៌មាន៖**


- លោក គល់ បញ្ញា នាយកប្រតិបត្តិអង្គការខុមហ្វ្រែល (COMFREL) ០១២ ៩៤២ ០១៧
- លោកស្រី រស់ សុភាព នាយិកាប្រតិបត្តិអង្គការ GADC ០១២ ៦២៧ ៨៥៧
- លោក យ៉ង់ គិមអេង នាយកប្រតិបត្តិមជ្ឈមណ្ឌល PDP Center ០១៦ ៨២៨ ២១១
- លោក ហួន ជុនឌី នាយកប្រតិបត្តិស្តីទីមជ្ឈមណ្ឌល CLEC ០៩៣ ៣៤៥ ៦០២
- លោក នី ចរិយា ប្រធានផ្នែកស៊ើបអង្កេតនៃ សមាគមអាដហុក ០១១ ២៧៤ ៩៥៩